**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ២៧/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្តព្រះសីហនុ

*ភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៩៦នាក់ មកពីស្រុកនានា និងក្រុងនៅក្នុងខេត្តព្រះសីហនុ ដែលក្នុងនោះមានសិក្ខាកាមស្ត្រីចូលរួម ប្រមាណ ១៣% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រះសីហនុ កាលពីថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៩ ។

លោក **សេរី សម្បត្តិ** នាយរងខុទ្ទកាល័យសាលាខេត្តព្រះសីហនុបានមានប្រសាសន៍បើកសិក្ខាសាលាថា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានកំណត់វិធានការគោលនានាក៏ដូចជាវិស័យអាទិភាពនានាដើម្បីអភិវឌ្ឍកម្ពុជាទាំងផ្នែកសេដ្ឋកិច្ច ស្ថេរភាពនយោបាយ សន្តិសុខ ធនធានមនុស្សសំរាប់ប្រទេសជាតិទាំងមូល។ ហើយសិក្ខាសាលានេះក៏ជាការផ្សារភ្ជាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលទៅអោយមន្ត្រីជាប់ឆ្នោតផងដែរ ។

សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **វង្ស ផាណាត** មកពីគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **សុខ សាវ៉ាត** មកពីគណបក្សសមរង្ស៊ី បានទទួលយកលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ហើយឯកឧត្តមក៏បានលើកឡើងថា ប្រជាពលរដ្ឋបានកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពរួចហើយ បន្ទាប់មកប្រជាពលរដ្ឋគួរតែធ្វើការតាមដានថា តើរាជរដ្ឋាភិបាលធ្វើអ្វីបានខ្លះ ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តព្រះសីហនុដូចខាងក្រោម:

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើត ស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

| លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនាំងដប់នៅក្នុងខេត្ត  ព្រះសីហនុ |
|---|
| ១) សុំអោយបង្កើត និងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ អោយបាននៅឆ្នាំ ២០១០។ |
| ២) សុំជួសជុលផ្លូវលំ និងផ្លូវជាតិ ដោយធ្វើពីបេតុង ឬកៅស៊ូ ឱ្យបានទូទាំងខេត្តព្រះសីហនុ ចាប់ពីឆ្នាំ២០១០ ឱ្យហើយរួចរាល់នៅឆ្នាំ ២០១២។ |
| ៣) សុំតប្រព័ន្ធអគ្គីសនីឱ្យបានទូទាំងខេត្តព្រះសីហនុ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២ ដោយមានតំលៃចន្លោះពី ៥០០រៀល ទៅ៧០០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ហើយមានភ្លើងអគ្គីសនីប្រើប្រាស់គ្រប់២៤ម៉ោង។ |
| ៤) សុំដីសម្បទានសង្គមកិច្ចដល់គ្រប់គ្រួសារគ្មានដីនៅទូទាំង ខេត្តព្រះសីហនុ អោយបានចាប់ពីឆ្នាំ ២០១០ ដល់ ២០១២ អោយបានគ្រប់គ្រួសារ ដោយក្នុង១ គ្រួសារ អោយបាន ១ ហិចតា។ |
| ៥) រដ្ឋាភិបាលមុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់អ្នកវិនិយោគត្រូវអនុវត្តលើការសិក្សាពីទីតាំងផ្តល់ដីអោយបានច្បាស់លាស់ និងវាយតំលៃពីផលប៉ះពាល់ផ្នែកបរិស្ថាន ព្រមទាំងធ្វើការផ្សព្វផ្សាយពីគំរោងត្រូវអភិវឌ្ឍន៏នឹងផ្សព្វផ្សាយរបាយការណ៏ស្តីពីផលប៉ះពាល់ឱ្យដល់តំបន់ដែលត្រូវអភិវឌ្ឍន៏ មុនពេលអនុវត្តគំរោង តាមរយៈសារពិតមាន វិទ្យុ ទូរទស្សន៏ សិក្ខាសាលា ប្រជុំដោយអនុវត្តចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) សេវាព្យាបាលជម្ងឺ (ជំងឺគ្រុនឈាម គ្រុនពោះវៀន វះកាត់ពេលឆ្លងទន្លេ) នៅមន្ទីរពេទ្យរដ្ឋ ជូនប្រជាពលរដ្ឋមិនត្រូវយកប្រាក់ទូទាំងខេត្តព្រះសីហនុ ចាប់ពី ឆ្នាំ២០១០ តទៅ។ |
| ៧) បំបាត់ការយកលុយពេលប្រលងឌីប្លូម បាក់ឌុប និងការបង្រៀនគួរក្នុងម៉ោងរដ្ឋ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៨) សុំអោយមានការដាក់តារាងកំណត់តំលៃអោយបានជាក់លាក់សំរាប់ប្រជាពលរដ្ឋដែលត្រូវការដោះស្រាយទំនាស់តាមផ្លូវតុលាការ (ប្រាក់ប្រដាប់ក្តី ប្រាក់ចុះបញ្ជីពាក្យបណ្តឹង...) នៅខេត្តព្រះសីហនុអោយបាននៅឆ្នាំ ២០១០ តទៅ។ |
| ៩) សុំវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសកសិកម្មដំណាំស្រូវ ស្លែ ផ្សិត សាលាដ និងសត្វពាហនៈ ដូចជាគោ ជ្រូក ក្របី ក្នុង១ ឆ្នាំអោយបាន ២ វគ្គ ដល់កសិករអោយបានទូទាំងខេត្ត ព្រះសីហនុ ចាប់ពីឆ្នាំ២០១០ តទៅ។ |
| ១០) សុំអោយមានការបិទផ្សាយជាសាធារណៈអោយប្រជាពលរដ្ឋដឹងពីតំលៃសេវា និងរយៈពេលដែលត្រូវទទួលបានសេវា ដែលប្រជាពលរដ្ឋចង់បានដូចជា (សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ ការសរសេរពាក្យបណ្តឹង ការសំរុះសំរួលទំនាស់,,.) ធ្វើអោយបានគ្រប់ឃុំ ចាប់ផ្តើមពីឆ្នាំ ២០១០។ ត្រូវមានការពិភាក្សាគ្នាជាមុនរវាងប្រជាពលរដ្ឋអោយបានគ្រប់ឃុំដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន មុននឹងសំរេចចិត្តបោះបង្គោល ឬផ្តល់ការវិនិយោគ ឬកំនត់តំបន់ការពារ ឬការផ្តល់សម្បទានសេដ្ឋកិច្ច ដោយអនុវត្តចាប់ផ្តើមពីឆ្នាំ ២០១០ តទៅ។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល (COMFREL) សហការជាមួយសមាគមការពារសិទ្ធិមនុស្ស អាដហុក (ADHOC), អង្គការស្រាវជ្រាវជាតិកម្ពុជា (CNRO), សមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម (KKKHRA), សម្ព័ន្ធការពារធនធានធម្មជាតិ (FACT) ដែលក្នុងនោះ មានការចូលរួម ពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៏ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកព្រៃនប់ ស្រុកស្ទឹងហាវ និងក្រុងព្រះសីហនុ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៏នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំន្ទ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦